ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៣៤០៥ ព.ណ.ស.ជ

ថ្ងៃអង្គារ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២៣

សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាផលិតករ ឬអ្នកនាំចេញទោចក្រយានទាំងអស់ឱ្យបានជ្រាបថា យោងតាមការស្នើសុំរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រើប្រាស់វិធានបូកបន្ថែម (Extended Cumulation) ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម សហភាពអឺរ៉ុប បានសម្រេចឱ្យប្រើវិធានបូកបន្ថែមនេះ តាមសេចក្តីសម្រេចលេខ (EU) 2023/1810 ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ របស់គណៈកម្មការអឺរ៉ុប។

វិធានបូកបន្ថែមនេះ អនុញ្ញាតឱ្យប្រទេសកម្ពុជាអាចប្រើប្រាស់ «**វត្ថុធាតុដើមឬគ្រឿងបង្គុំទោចក្រយាន**» ដែលមានដើមកំណើតនៅប្រទេសវៀតណាម សម្រាប់យកមកផលិតទោចក្រយាននៅប្រទេសកម្ពុជា ដើម្បីនាំចេញទៅសហភាពអឺរ៉ុប។ ការប្រើប្រាស់វត្ថុធាតុដើមឬគ្រឿងបង្គុំដូចមានចែងក្នុងឧបសម្ព័ន្ធ I សម្រាប់ផលិតទោចក្រយានដូចមានចែងក្នុងឧបសម្ព័ន្ធ II នៃសេចក្តីសម្រេចនេះ ត្រូវអនុលោមតាមវិធានដើមកំណើតទំនិញស្ថិតក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហភាពអឺរ៉ុប (EU's GSP)។

ផលិតករ ឬអ្នកនាំចេញទោចក្រយានទាំងអស់ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មនូវបរិមាណនៃការប្រើប្រាស់វត្ថុធាតុដើមឬគ្រឿងបង្គុំដែលនាំចូលពីប្រទេសវៀតណាម ប្រចាំឆមាស និងត្រូវធ្វើរបាយការណ៍ស្តីពីការប្រើប្រាស់វត្ថុធាតុដើមឬគ្រឿងបង្គុំ ប្រចាំត្រីមាស មកក្រសួងពាណិជ្ជកម្ម (ដូចមានគំរូលិខិតស្នើសុំ និងគំរូរបាយការណ៍ជូនភ្ជាប់) ដើម្បីក្រសួងមានមូលដ្ឋានក្នុងការជូនដំណឹងទៅសហភាពអឺរ៉ុប។

ចំពោះព័ត៌មានលម្អិត សូមចូលគេហទំព័រ https://eur-lex.europa.eu/eli/dec/2023/1810/oj ឬទំនាក់ទំនងមក អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម៖

ទូរស័ព្ទ៖ ០១២ ៨៣៨ ៩០៩/ ០១២ ៨៣៣ ៣៩៧/ ០១២ ៩៤៨ ៤៨៤/ ០១៧ ៤៥៥ ៥១២
អ៊ីមែល៖ hosivyong@yahoo.com/ unchantha2017@gmail.com/ batithsy@yahoo.com/ kaodauch@gmail.com/ exportimportdept@moc.gov.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាផលិតករ ឬអ្នកនាំចេញទោចក្រយានទាំងអស់ជ្រាបជាព័ត៌មាន។

ស្នែនដើម្បីទទួលបានព័ត៌មានលម្អិត **ស្នែនដើម្បីទាញយកឯកសារ**

សូមអរគុណ!